# English for Study in Australia

# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## Lesson 12: Getting around

## មេរៀនទី១២ ៖ ការធ្វើដំណើរ**ពីកន្លែងមួយទៅកន្លែងមួយ**

| | |
|---|---|
| **L1 Male** | *សួស្តី ខ្ញុំឈ្មោះ យុទ្ធ ឈាង...* |
| **L1 Female** | *... ហើយខ្ញុំប៊ុន ឡឺវីសីដា នៃវិទ្យុអូស្ត្រាលី។* |
| **L1 Male** | *សូមស្វាគមន៍លោក លោកស្រី និងប្រិយមិត្តទាំងអស់ជាថ្មីម្តងទៀត នៅក្នុងកម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលីដែលចងក្រងឡើងដោយសេវាអប់រំពហុវប្បធម៌សម្រាប់មនុស្សពេញវ័យ (AMES) នៅទីក្រុងមែលប៊ិន ប្រទេសអូស្ត្រាលី។* |
| | |
| **L1 Female** | *មេរៀនទី១២ ៖ ការធ្វើដំណើរពីកន្លែងមួយទៅមួយ*<br>*នៅក្នុងមេរៀននេះ លោកអ្នកនឹងរៀនអំពីការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយនៅក្នុងបណ្តាក្រុងទាំងឡាយនៃប្រទេសអូស្ត្រាលី។ លោកអ្នកក៏នឹងសិក្សាផងដែរអំពីគុណសម្បត្តិ និងគុណវិបត្តិនៃប្រភេទមធ្យោបាយធ្វើដំណើរមួយចំនួន និងរបៀបប្រឡងយកប័ណ្ណបើកបរ។* |
| **L1 Male:** | *ឥឡូវនេះសូមចាប់ផ្តើម។ ជាដំបូង លោកអ្នកនឹងឮការសន្ទនាដោយមានការបកប្រែជូន។ លោកអ្នក នឹងមានឱកាសហាត់រៀនពាក្យពេចន៍ និងឃ្លាប្រយោគសំខាន់ៗ នៅក្នុងមេរៀននាពេលបន្តិចទៀតនេះ។ ក៏ប៉ុន្តែ ដើម្បីឲ្យឆាប់ចាំស្ទាត់ ខ្ញុំស្នើសុំឲ្យលោកអ្នកហាត់អនុវត្តថាតាមការសន្ទនាទាំងមូលដោយខ្លួនលោកអ្នកផ្ទាល់ ពីព្រោះពាក្យពេចន៍ និងឃ្លាប្រយោគទាំងនេះ ជាការប្រើប្រាស់ភាសាអង់គ្លេសតាមបែបអូស្ត្រាលីសុទ្ធសាធតែម្តង ហើយលោកអ្នកអាចដកស្រង់ការសន្ទនាទាំងស្រុងជាភាសាអង់គ្លេស ចេញពីវ៉ិបសាយថ៍របស់វិទ្យុអូស្ត្រាលី។*<br>*នៅក្នុងមេរៀននេះ រ៉ុកឃីទៅដល់ផ្ទះនៅពេលជិតភ្លឺ។ ឪពុកម្តាយគ្រួសារជនជាតិអូស្ត្រាលី ដែលរ៉ុកឃីមកស្នាក់នៅជាមួយ មានការព្រួយបារម្ភចំពោះរ៉ុកឃីយ៉ាងខ្លាំង។ ចន បានឮសំឡេងរ៉ុកឃីដើរចូលមក។* |

ABC Radio Australia


© RadioAustralia/AMES 2008

| | |
|---|---|
| Rocky: | Ouch! |
| John: WHISPERING | Rocky is that you? |
| L1: | *រ៉ុកឃី តើឯងមែនទេហ្នឹង?* |
| | |
| John: | Where’ve you been? It’s almost morning. Carmel’s been really worried about you. |
| L1: | *តើឯងទៅឯណា? នេះជិតភ្លឺហើយណ៎ា។ ដឹងទេថា ខា ម៉ល បារម្ភពីរូបឯងខ្លាំងណាស់។* |
| Rocky: | I missed the last bus. |
| L1: | *ខ្ញុំខកជើងឡានក្រុងចុងក្រោយ។* |
| John: | What, you couldn’t have rung? |
| L1: | *ថាម៉េច! ចុះឯងមិនអាចទូរស័ព្ទមកប្រាប់ទេឬ?* |
| Rocky: APOLOGETIC | I forgot to charge my phone. |
| L1: | *គឺខ្ញុំភ្លេចសាកទូរស័ព្ទខ្ញុំហ្នឹងណ៎ា។* |
| John | So how’d you get home? |
| L1: | *ហើយអីចឹងឯងធ្វើម៉េចបានមកដល់ផ្ទះ?* |
| | |
| Rocky: | I walked… from St Kilda. |
| L1: | *គឺខ្ញុំដើរហ្នឹងណា...ពី St Kilda មកនោះអី។* |
| | |
| John: | You’re joking! That’s about 12 k! |
| L1: | *និយាយលេងទេដឹង! ពីនោះមកដល់ទីនេះ ចម្ងាយ១២គីឡូម៉ែត្រឯណោះណ៎ា!* |
| Rocky: | You’re telling me! I’ve gotta get a car. |


© RadioAustralia/AMES 2008

| | |
|---|---|
| L1: | *ខ្ញុំដឹងតើ! ខ្ញុំត្រូវមានឡានមួយប្រើហើយទើបបាន។* |
| John: DISCOURAGING | Oh, you'd be opening up a can of worms there! |
| L1: | *អីយ៉ា ឯងចាប់ផ្ដើមនាំបញ្ហាដាក់ខ្លួនហើយនេះ!* |
| Rocky: | How's that? |
| L1: | *ម៉េចបានទៅជាអីចឹង?* |
| John: | Well, first you've got to find a good one, and they're not that cheap. |
| L1: | *ដំបូងឡើយឯងត្រូវពិនិត្យរកមើលឡានដែលល្អហើយឡានដែលល្អមិនជាថោកប៉ុន្មានទេរ៉ើយ។* |
| Rocky: | Well they're a lot cheaper than at home. And I can sell it when I go. |
| L1: | *ឡាននៅទីនេះថោកៗជាងនៅប្រទេសខ្ញុំច្រើនណាស់។ ហើយ ខ្ញុំអាចលក់វាបានតើ នៅពេលដែលខ្ញុំត្រឡប់ទៅស្រុកខ្ញុំវិញនោះ។* |
| John: | Yeah but you've got onroad costs. Petrol, insurance, maintenance. Have you driven before? |
| L1: | *វាអីចឹងមែនហើយ ប៉ុន្តែ ឯងក៏ត្រូវចំណាយលើការប្រើប្រាស់ដែរ ដូចជា ថ្លៃសាំង ថ្លៃធានារ៉ាប់រង ការជួសជុល។ ហើយចុះឯងធ្លាប់បើកបរពីមុនមកទេ?* |
| Rocky: | No. But I can ride a scooter. How hard can it be? |
| L1: | *មិនធ្លាប់ផង។ ប៉ុន្តែខ្ញុំចេះជិះម៉ូតូ ឡាំប៉ាតា។ តើមានអីពិបាកទៅ?* |
| John: | So you'll have to get a licence. |
| L1: | *អីចឹងឯងត្រូវប្រឡងយកប័ណ្ណបើកបរសិន។* |
| Rocky: | Piece of cake. |
| L1: | *មានទៅពិបាកអី!* |
| John: | And before that you'll have to get your learner's permit. |



© RadioAustralia/AMES 2008

| | |
|---|---|
| L1: | *ហើយមុនហ្នឹងទៀត ឯងក៏ត្រូវទៅប្រឡងយកបណ្ណរៀនបើកបរសិនដែរ។* |
| Rocky: | Oh come on! |
| L1: | *អ្ហើយ ចុះមានរឿងអីដែលពិបាកនោះ!* |
| John: | Rocky, it took me ages to get my licence and to save for a car. And I only take it out when I really need to go long distances. It's too expensive. |
| L1: | *រ៉ុកឃី ឯងដឹងទេថា ខ្ញុំត្រូវចំណាយពេលយូរណាស់ណា ដើម្បីបានបណ្ណបើកបរ និងទម្រាំសន្សំបានប្រាក់ទិញឡានបាននោះ។ ហើយខ្ញុំប្រើវា តែនៅពេលដែលខ្ញុំត្រូវធ្វើដំណើរផ្លូវឆ្ងាយប៉ុណ្ណោះ។ ព្រោះវាត្រូវចំណាយប្រាក់ច្រើនហួសហេតុ។* |
| Rocky: | You mean petrol? |
| L1: | *ឯងចង់មានន័យថា ចំណាយទៅលើថ្លៃសាំងមែនទេ?* |
| John: | Petrol *and* parking. I'd rather ride my bike or take public transport. |
| L1: | *ទាំងថ្លៃសាំង ទាំងថ្លៃចត។ ខ្ញុំសុខចិត្តជ្រើសរើសយកការជិះកង់ ឬប្រើយានយន្តដឹកជញ្ជូនសាធារណៈវិញ។* |
| Rocky: | Hmm, maybe a bike's the go. |
| L1: | *អឺម...កង់ក៏អាចជាគំនិតមួយល្អម៉្យាងដែរ។* |
| John: | Yep. But you'll still need to know some road rules. |
| L1: | *មែនហើយ ប៉ុន្តែឯងក៏ត្រូវដឹងអំពីច្បាប់បើកបរដែរ។* |
| Rocky: DISBELIEF | What? I have to take a test to ride a bike? |
| L1: | *ថាម៉េចហ្នឹង? អីចឹងបើខ្ញុំជិះកង់ក៏ត្រូវធ្វើតេស្តដែរឬ?* |
| John: EMPHATICALLY | Nooooh! But you have to get used to the roads here. |
| L1: | *ទេ...! ប៉ុន្តែ ឯងត្រូវរៀនជិះដើម្បីឲ្យស៊ាំនឹងផ្លូវនៅទីនេះសិននោះអី។* |

ABC Radio Australia


© RadioAustralia/AMES 2008

| | |
|---|---|
| Carmel:<br>SLEEPY, IN DISTANCE | Rocky? Is that you? |
| L1: | រ៉ុកឃី? តើឯងមែនទេ? |
| Rocky: | Yes, Carmel, I missed the last bus.  Sorry. |
| L1: | បាទមែនហើយ ខាម៉ែល។ ខ្ញុំខកជើងឡានក្រុងចុងក្រោយ។ សុំទោសផងណា៎។ |
| Carmel: | As long as you're safe.  We'll talk about it in the morning.  Good night. |
| L1: | ឲ្យតែឯងមានសុវត្ថិភាពនោះ វា មិនអីទេ។ ចាំ យើងនិយាយគ្នាអំពីរឿងនេះនៅព្រឹកស្អែកចុះណា៎។ រាត្រីសួស្តី។ |
| Rocky: | Good night. |
| L1: | រាត្រីសួស្តី។ |
| | |
| John:<br>WHISPERS | Tell you what.  You get yourself a bike and helmet and I'll take you for a ride…  show you the best way to get to the city. |
| L1: | ខ្ញុំប្រាប់រឿងមួយ។ ឯងទិញ កង់ និងមួកសុវត្ថិភាពមួយទៅ ចាំខ្ញុំ នាំឯងជិះមើលផ្លូវណាដែលប្រសើរបំផុតសម្រាប់ជិះចូលទៅក្នុងទីក្រុង។ |
| Rocky: | Cool! So where do I get a good bike? |
| L1: | ល្អណាស់! អីចឹងខ្ញុំទៅទិញកង់ដ៏ល្អមួយនៅកន្លែងណាទៅ? |
| John:<br>YAWNS | Aah.  Let's talk about it in the morning.  I've got to get some sleep. |
| L1: | អ្ហ៎ា ចាំនិយាយគ្នានៅព្រឹកស្អែកចុះ។ ខ្ញុំត្រូវការគេងខ្លះសិនហើយ។ |


© RadioAustralia/AMES 2008

**L1 Male:**

*ការស្វែងយល់អំពីកិច្ចសន្ទនា។*

*ការទិញឡាន គឺជាជម្រើសមួយសម្រាប់អ្នកធ្វើដំណើរនៅប្រទេសអូស្ត្រាលី ជាពិសេស ប្រសិនបើពួកគេចង់ធ្វើដំណើរឆ្លងរដ្ឋ ឬទីកន្លែងឆ្ងាយៗ។ ជាញឹកញាប់ ក្រុមនិស្សិតច្រើនចូលលុយគ្នា រួចទិញឡានដែលគេប្រើហើយមួយ ដើម្បីជិះរួមគ្នា។ ប៉ុន្តែដូចដែលចនបានលើកឡើងអីចឹង ការជិះឡាន ត្រូវចំណាយប្រាក់ច្រើនណាស់។ ប្រសិនបើលោកអ្នកជ្រើសរើសការទិញឡាន សូមស្តាប់យោបល់អ្នកជំនាញការដើម្បីទៅទិញឡាននៅកន្លែងដ៏ល្អបំផុត។*

*នៅរដ្ឋវិកថូរៀ ប្រសិនបើលោកអ្នកកាន់ទិដ្ឋាការនិស្សិត ហើយលោកអ្នកមានប័ណ្ណបើកបរពីប្រទេសរបស់លោកអ្នករួចហើយនោះ សូមយកមកជាមួយនូវលិខិតបើកបរនោះដោយបកប្រែជាភាសាអង់គ្លេស ឬលិខិតអនុញ្ញាតឲ្យបើកបរជាអន្តរជាតិ។ លោកអ្នកអាចបើកឡានបាន នៅរយៈពេលដែលលោកអ្នកស្នាក់នៅទីនេះ។*

*សម្រាប់លោកអ្នកដែលមានទិដ្ឋាការអចិន្ត្រៃយ៍ អាចបើកបរបានយ៉ាងយូរបំផុត៣ខែ។ បន្ទាប់ពីនោះមក លោកអ្នកអាចបើកបរបាន លុះណាតែលោកអ្នកមានប័ណ្ណបើកបរក្នុងនាមជាពលរដ្ឋរស់នៅក្នុងរដ្ឋវិកថូរៀប៉ុណ្ណោះ។*

*ច្បាប់បើកបរ និងលក្ខខណ្ឌនៃប័ណ្ណបើកបរ គឺខុសគ្នាពីរដ្ឋមួយទៅរដ្ឋមួយទៀត។ ដើម្បីជួយលោកអ្នកក្នុងការស្វែងយល់ពីច្បាប់ទម្លាប់ដ៏ត្រឹមត្រូវនៅក្នុងទីក្រុងដែលលោកអ្នកទៅលេង ឯកសារជំនួយមេរៀននៅក្នុងមេរៀននេះនឹងបង្ហាញអំពីការភ្ជាប់ទៅនឹងសមត្ថកិច្ចចរាចរណ៍របស់រដ្ឋាភិបាលនៅតាមរដ្ឋនីមួយៗ។*


© RadioAustralia/AMES 2008

**L1 Female:**

នៅរដ្ឋវិកថូរៀ ដើម្បីទទួលបានប័ណ្ណបើកបរ លោកអ្នកត្រូវចំណាយពេលវេលាច្រើន។ មុនពេលលោកអ្នកអាចអង្គុយនៅក្នុងកៅអីអ្នកបើកបរបាន លោកអ្នកត្រូវមានប័ណ្ណអនុញ្ញាតជាមុនសិន។ ហើយដើម្បីទទួលបានប័ណ្ណអនុញ្ញាតឲ្យរៀនបើកបរ លោកអ្នកត្រូវសិក្សាអំពីសៀវភៅបើកបរហៅជាភាសាអង់គ្លេសថា Road to Solo Driving និងឆ្លងកាត់ការធ្វើតេស្តកុំព្យូទ័រ និងតេស្តភ្នែកឲ្យជាប់សិន។ ហើយប្រសិនបើលោកអ្នកមានអាយុក្រោម២៥ឆ្នាំ និងគ្មានប័ណ្ណបើកបរពីមុនមក លោកអ្នកត្រូវមានលិខិតអនុញ្ញាតឲ្យរៀនបើកបរយ៉ាងហោចណាស់ក៏៦ខែ មុនពេលលោកអ្នកទទួលបានប័ណ្ណបើកបរក្នុងដំណាក់កាលសាកល្បងដែរ។

លោកអ្នកត្រូវរៀនបើកបរចំនួន១២០ម៉ោង ជាមួយអ្នកបើកបរដែលមានបណ្ណ័បើកបរពេញលេញ និងធ្វើតេស្តវាស់កម្រិតសមត្ថភាពយល់ដឹងអំពីគ្រោះថ្នាក់តាមកុំព្យូទ័រ ក៏ដូចជាធ្វើតេស្តភ្នែក និងតេស្តលើការអនុវត្តការបើកបរជាមួយអ្នកវាយតម្លៃរបស់រដ្ឋាភិបាល។

លោកអ្នកអាចដកស្រង់យកសៀវភៅ Road to Solo Driving និងសាកល្បងធ្វើតេស្តអនុវត្តដើម្បីយកប័ណ្ណបើកបរ តាមរយៈវិបសាយថ៍ VicRoads ដែលមានបង្ហាញនៅក្នុងឯកសារជំនួយមេរៀន។

**L1 Male:**

ការហាត់រៀនភាសា។

ថ្ងៃនេះ យើងនឹងហាត់រៀនភាសាដែលលោកអ្នកត្រូវប្រើប្រាស់សម្រាប់ធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ។

ជាដំបូង លោកអ្នកនឹងឮការបកប្រែ បន្ទាប់មកសូមស្តាប់ រួចថាតាមជាភាសាអង់គ្លេស។

**L1:** អត់ទោស តើឡានក្រុងនេះទៅ Northland មែនទេ?

**English:** Excuse me, does this bus go to Northland?(PAUSE)

**L1:** តើអ្នកអាចប្រាប់ខ្ញុំបានទេ ថាពេលណាទើបយើងទៅដល់ផ្លូវ Main St ?

**English:** Could you tell me when we get to Main Street, please? (PAUSE)


© RadioAustralia/AMES 2008

| | |
|---|---|
| **L1:** | *តើឡានក្រុងទាំងនេះធ្វើដំណើរទៅ Box Hill ញឹកញាប់ប៉ុនណាដែរ?* |
| **English:** | How often do the buses run to Box Hill? (PAUSE) |
| **L1:** | *អត់ទោស តើចំណតឡានក្រុងទៅកាន់ទីក្រុង នៅកន្លែងណាដែរ ដែលនៅជិតជាងគេបំផុត?* |
| **English:** | Excuse me, where’s the nearest bus stop to the city? (PAUSE) |
| **L1:** | *តើរថយន្តក្រុងចុងក្រោយគេចេញនៅម៉ោងប៉ុន្មាន?* |
| **English:** | What time does the last bus leave? (PAUSE) |
| **L1:** | *តើចំណតរថភ្លើងមួយណាដែលខ្ញុំត្រូវរង់ចាំ ដើម្បីជិះរថភ្លើងទៅកាន់ Epping ?* |
| **English:** | Which platform do I need for the Epping line train? (PAUSE) |
| **L1:** | *តើសំបុត្រមួយណាដែលខ្ញុំត្រូវទិញ ដើម្បីទៅ Ringwood?* |
| **English:** | Which ticket do I need to get to Ringwood? (PAUSE) |
| **L1:** | *តើរទេះភ្លើងនេះឈប់នៅ Richmond ទេ?* |
| **English:** | Does this train stop at Richmond? (PAUSE) |
| **L1:** | *តើខ្ញុំត្រូវចុះនៅកន្លែងណា ដើម្បីទៅសារមន្ទីរ?* |
| **English:** | Where do I get off for the museum? (PAUSE) |
| **L1:** | *អត់ទោស តើកន្លែងណាទៅ ដែលខ្ញុំត្រូវជិះសាឡាងទៅ Manly បាននោះ?* |
| **English:** | Excuse me, where do I catch the ferry to Manly? (PAUSE) |
| **L1:** | *តើឡានត្រែមមួយណាទៅដែលនឹងដឹកខ្ញុំទៅ Carlton នោះ?* |
| **English:** | Which tram will take me to Carlton? (PAUSE) |

| | |
|---|---|
| **L1 Male:** | *ឥឡូវនេះ សូមស្តាប់និស្សិតជជែកគ្នានៅតាមដងផ្លូវ!* |


© RadioAustralia/AMES 2008

| | |
|---|---|
| **Interviewer:** | សូមទោស? |
| **Female Student:** | ចាសមានការអ្វីដែរ? |
| **Interviewer:** | តើអ្នកមានពេលឆ្លើយសំណួរដ៏ខ្លីមួយឲ្យវិទ្យុអូស្ត្រាលីបានទេ? |
| **Female Student:** | ចាសមានអី។ |
| **Interviewer:** | តើអ្នកប្រើពេលយូរប៉ុណ្ណាដែរ ដើម្បីសិក្សាឲ្យយល់ដឹងច្បាស់អំពីប្រព័ន្ធធ្វើដំណើរសាធារណៈនៅទីនេះ? |
| **Female Student:** | ខ្ញុំមិនដែលភ្លេចបទពិសោធន៍លើកទី១ ពេលដែលខ្ញុំបានធ្វើដំណើរតាមយានយន្តសាធារណៈនោះទេ។ ការពិតខ្ញុំចង់ទៅ Emerald Hill ដើម្បីទៅលេងបងប្អូន ដែលខ្ញុំមិនធ្លាប់បានជួបសោះពីមុនមក។ ខ្ញុំបានសួរបុរសម្នាក់នៅឯស្ថានីយ អំពីទិសដៅធ្វើដំណើរទៅទីកន្លែងនោះ ហើយគាត់មើលទៅដូចជាយកចិត្តទុកដាក់ខ្នះខ្នែងជួយខ្លាំងណាស់។ ដូចនេះ ខ្ញុំក៏បានឡើងជិះរថភ្លើង បន្ទាប់មកក៏ឡើងជិះឡានក្រុង។ ២ម៉ោងក្រោយមក ក៏បានមកដល់តំបន់ភ្នំឯណាឯណីទៅវិញ! |
| **Interviewer:** | គួរឲ្យចម្លែកណាស់ Emerald Hill គឺជាកន្លែងមួយបិតនៅប៉ែកខាងត្បូងនៃទីក្រុងមែលប៊ិនទេតើ។ ហើយដូចជាមិននៅក្បែរភ្នំសោះហើយ។ |
| **Female Student:** | អត់ទេ ប៉ុន្តែ មានកូនទីប្រជុំជនមួយដែលមានឈ្មោះថា Emerald គឺនៅក្នុងតំបន់ភ្នំតែម្តង! |
| **Interviewer:**<br>**LAUGHS** | អ្ហ៎ខ្ញុំយល់ហើយ! បុរសនៅស្ថានីយនោះពិតជាស្តាប់ច្រឡំនូវអ្វីដែលនាងនិយាយ! |
| **Female Student:** | ឬប្រហែលមកពីខ្ញុំនិយាយមិនបានច្បាស់លាស់ហើយមើលទៅ។ |
| **Interviewer:** | តែទោះជាយ៉ាងណា ក៏ Emerald ជាកន្លែងដែលស្អាតគួរឲ្យចង់ទៅលេងដែរតើ មិនថាអីចឹងហ្អី? |


© RadioAustralia/AMES 2008

| | |
|---|---|
| **Female Student:** | មែនហើយ ប៉ុន្តែខ្ញុំខកខានមិនបានទៅជួបបងប្អូនជីដូនមួយរបស់ខ្ញុំ។ ឥឡូវបើខ្ញុំចង់ទៅទីកន្លែងណាថ្មីដែលខ្ញុំមិនដែលស្គាល់ ខ្ញុំត្រូវរកមើលផែនទីផ្លូវ ឬឆែកតាមអ៊ីនធើរណិតមើលជាមុនសិន។ |
| **Interviewer:** | ធ្វើអីចឹងក៏ល្អដែរ។ អរគុណចំពោះពេលវេលារបស់នាង ហើយសូមឲ្យការធ្វើដំណើររបស់នាងទៅថ្ងៃមុខប្រកបដោយភាពរីករាយ។ |
| **Female Student:** | ចាស អរគុណហើយ។ |
| | |
| **L1 Male** | និស្សិតម្នាក់នេះ បានរៀនរៀបចំខ្លួនយ៉ាងប្រសើរមុននឹងធ្វើដំណើរ។ ទីក្រុងភាគច្រើនមានវ៉ិបសាយថ៍ ដែលលោកអ្នកអាចស្វែងរកព័ត៌មានសំខាន់ៗ និងតំបន់ក៏ដូចជាគោលដៅ ដែលលោកអ្នកចង់ទៅ ព្រមទាំងអាចស្វែងយល់អំពីពេលវេលា និងទីកន្លែងនៃមធ្យោបាយធ្វើដំណើរតាមយានយន្តសាធារណៈ ដែលនាំលោកអ្នកទៅដល់កន្លែងដែលលោកអ្នកចង់ទៅ។ |


© RadioAustralia/AMES 2008

**EXERCISE**
**លំហាត់**

| | |
|---|---|
| **L1 Female** | *ការហាត់រៀនកិច្ចសន្ទនា។ ឥឡូវនេះ លោកអ្នក នឹងឮផ្នែកមួយនៃការសន្ទនា នៅក្នុងមេរៀនថ្ងៃនេះ ជាភាសាអង់គ្លេស។ លោកអ្នក នឹងមានពេលថាតាម ប្រយោគនីមួយៗរបស់ រ៉ុកឃី។ សូមស្តាប់ រួចថាតាម។* |

| | |
|---|---|
| John: | Rocky is that you? |
| John: | Where've you been? It's almost morning. Carmel's been really worried about you. |
| Rocky: | I missed the last bus. (PAUSE) |
| John: | What, you couldn't have rung? |
| Rocky: | I forgot to charge my phone. (PAUSE) |
| John | So how'd you get home? |
| Rocky: | I walked… from St Kilda. (PAUSE) |
| John: | You're joking! That's about 12 k! |
| Rocky: | You're telling me! I've gotta get a car. (PAUSE) |
| John: | Oh, you'd be opening up a can of worms there! |
| Rocky: | How's that? (PAUSE) |
| John: | Well, first you've got to find a good one, and they're not that cheap. (PAUSE) |
| Rocky: | Well they're a lot cheaper than at home. And I can sell it when I go. (PAUSE) |
| John: | Yeah but you've got onroad costs. Petrol, insurance, maintenance. Have you driven before? |
| Rocky: | No. But I can ride a scooter. How hard can it be? (PAUSE) |
| John: | So you'll have to get a licence. |
| Rocky: | Piece of cake. (PAUSE) |


© RadioAustralia/AMES 2008

| | |
|---|---|
| John: | And before that you'll have to get your learner's permit. |
| Rocky: | Oh come on! (PAUSE) |
| John: | Rocky, it took me ages to get my licence and to save for a car. And I only take it out when I really need to go long distances. It's too expensive. |
| Rocky: | You mean petrol? |
| John: | Petrol and parking. I'd rather ride my bike or take public transport. |
| Rocky: | Hmm, maybe a bike's the go. |

ABC Radio Australia


© RadioAustralia/AMES 2008

| | |
|---|---|
| **L1 Female:** | គ្រប់ទីក្រុងនៅប្រទេសអូស្ត្រាលី មានសេវាឡានក្រុង និងរទេះភ្លើងច្រើនណាស់។ ទីក្រុងមែលប៊ិន ក៏មានឡានត្រែម ហើយនៅទីក្រុងស៊ីដនីយ៍ ក៏មានសាឡាង ដែលជារបៀបផ្សេងៗគ្នានៃមធ្យោបាយធ្វើដំណើរតាមយានយន្តសាធារណៈ។ ប្រភេទសំបុត្រ និងថ្លៃធ្វើដំណើរ មានកម្រិតខុសគ្នាពីរដ្ឋមួយទៅរដ្ឋមួយទៀត។ នៅរដ្ឋវិកថូរៀ ដោយឡែក ប្រព័ន្ធលក់សំបុត្រធ្វើដំណើរ គឺធ្វើឡើងដោយម៉ាស៊ីនស្វ័យប្រវត្តិ ប៉ុន្តែលោកអ្នកក៏អាចទិញសំបុត្រពីហាងនានា ដូចជា បណ្ណាគារ កន្លែងលក់ទំនិញបន្ទាប់បន្សំ ក៏ដូចជាម៉ាស៊ីននៅឯស្ថានីយជាដើម។ សម្រាប់រថយន្តត្រែមវិញ លោកអ្នកក៏អាចទិញសំបុត្រនៅលើរថយន្តបានដែរ។ អ្នកឆែកសំបុត្រ ដើរចូលពិនិត្យសំបុត្រដោយមិនបានគ្រោងទុកជាមុននៅលើរថភ្លើង និងឡានត្រែម ហើយភ្នាក់ងារឆែកសំបុត្រនេះនឹងធ្វើការផាកពិន័យ ប្រសិនលោកអ្នកគ្មានសំបុត្រត្រឹមត្រូវ។ ដូច្នេះលោកអ្នកត្រូវប្រាកដថា លោកអ្នកមានសំបុត្រត្រឹមត្រូវជាប់ជានិច្ច នៅពេលប្រើយានយន្តសាធារណៈ។ម្យ៉ាងវិញទៀត ប្រសិនបើអ្នកលោកអ្នកដាក់ជើងនៅលើកៅអី ឬស្តោះទឹកមាត់ ឬចោលសម្រាម ឬប្រើប្រាស់ពាក្យពេចន៍មិនគួរគប្បី នុះលោកអ្នកនឹងត្រូវទទួលនូវការផាកពិន័យយ៉ាងធ្ងន់ធ្ងរ។<br><br>ចំណុចមួយផ្សេងទៀតដែលខុសគ្នាពីរដ្ឋមួយទៅរដ្ឋមួយទៀតនោះគឺការចេញប័ណ្ណសម្បទាននិស្សិត។ នៅបណ្តារដ្ឋមួយចំនួន និស្សិតនៅសាលា ELICOS មានសិទ្ធិទទួលប័ណ្ណសម្បទាននិស្សិត ដែលបញ្ចុះតម្លៃសំបុត្រប្រើយានយន្តសាធារណៈឲ្យមកនៅត្រឹមពាក់កណ្តាលប៉ុណ្ណោះ។ ប្រសិនបើលោកអ្នកមានប័ណ្ណសម្បទាននិស្សិត លោកអ្នក ត្រូវយកវាជាប់តាមខ្លួនជានិច្ច។ សូមកុំច្រឡំប័ណ្ណនេះជាមួយប័ណ្ណសម្គាល់ខ្លួននិស្សិតនៅសាលារៀនឲ្យសោះ ដែលប័ណ្ណសម្គាល់និស្សិតប្រើប្រាស់សម្រាប់តែគោលបំណងរដ្ឋបាល និងសម្រាប់ខ្ចីសៀវភៅពីបណ្ណាល័យក្នុងសាលារៀនប៉ុណ្ណោះ។ |



© RadioAustralia/AMES 2008

| | |
|---|---|
| **L1 Male:** | *រ៉ុកឃី សម្រេចទិញកង់ ដែលជាជម្រើសដ៏ល្អមួយ។ ប្រទេសអូស្ត្រាលីសម្បូរទៅដោយទីក្រុងដែលយកចិត្តទុកដាក់នឹងបញ្ហាបរិស្ថាន ដូច្នេះ លោកអ្នកនឹងបានឃើញនូវការរក្សាទុកផ្លូវ ឬការសាងសង់ផ្លូវសម្រាប់ឲ្យមានការប្រើទោចក្រយាន ដើម្បីកាត់បន្ថយផ្សែងយានយន្ត ដែលជាកត្តាដ៏ចម្បងមួយក្នុងការបំពុលបរិស្ថាន។ យ៉ាងណាមិញ ច្បាប់តម្រូវឲ្យអ្នកជិះកង់ទាំងអស់ ពាក់មួកសុវត្ថិភាពដែលមានការទទួលស្គាល់ និងកុំភ្លេចទិញកង់ដែលមានសោមាំផងដែរ។ កង់របស់លោកអ្នកត្រូវមានពណ៌ចាំងៗ ដូចជាពណ៌សនៅផ្នែកខាងមុខ និងពណ៌ក្រហមនៅដៃចង្កូតដើម្បីងាយមើលឃើញ។ លោកអ្នកត្រូវប្រាកដថា លោកអ្នកស្លៀកសម្លៀកបំពាក់ណាដែលមានពណ៌ឆើតភ្លឺៗ ដើម្បីឲ្យអ្នកបើកបរដទៃមើលឃើញលោកអ្នកបានច្បាស់។*<br><br>*នៅរដ្ឋវិកថូរៀ អ្នកជិះកង់ ត្រូវដឹងអំពីវិន័យផ្លូវថ្នល់ឬចរាចរណ៍ ដូចអ្នកបើកកូនឡាន និងអ្នកបើកឡានធំដែរ។ នៅក្នុងឯកសារជំនួយមេរៀននៅក្នុងមេរៀននេះ លោកអ្នកនឹងបានឃើញការតភ្ជាប់ទៅនឹងវិបសាយថ៍ ដែលមានព័ត៌មានពាក់ព័ន្ធនឹងវិន័យសម្រាប់អ្នកជិះកង់។* |

| | |
|---|---|
| **L1 Female:** | *ឧបសគ្គក្នុងការប្រើប្រាស់ភាសា។ នៅក្នុងមេរៀននេះ លោកអ្នកនឹងហាត់រៀនអំពីបណ្តុំព្យញ្ជនៈនៅដើមពាក្យ។ អ្នកហាត់រៀនភាសាអង់គ្លេសមួយចំនួន មានការលំបាកក្នុងការបញ្ចេញសូរសំឡេងស្រៈខុសៗគ្នាក្នុងពេលតែមួយ។ ឧទាហរណ៍ ដូចជាពាក្យថា speak អាចអានខុសទៅជា "si-peak" ។ ជាដំបូងសូមហាត់រៀនភាសាអង់គ្លេសដែលងាយប្រទះឃើញជាញឹកញាប់ហើយក៏ងាយអានខុសដែរ។*<br><br>*សូមស្តាប់ រួចហើយថាតាម។* |


© RadioAustralia/AMES 2008

| | |
|---|---|
| **English:** | speak (PAUSE)<br>spoon (PAUSE)<br>street (PAUSE)<br>school (PAUSE)<br>tram (PAUSE)<br>train (PAUSE)<br>transport (PAUSE)<br>travel (PAUSE)<br>study (PAUSE)<br>blue (PAUSE) |
| **L1 Female:** | *ហើយឥឡូវនេះ ដល់ពេលហាត់ពត់អណ្តាតរបស់លោកអ្នកហើយ ដើម្បីខំនិយាយតាមពាក្យដ៏លំបាកដូចតទៅនេះ។ សូមស្តាប់ រួចថាតាមឱ្យបានច្រើនដងតាមដែលលោកអ្នកអាចធ្វើទៅបាន។* |
| English: | Travel to Spotswood by tram and train. (PAUSE)<br>Travel to Spotswood by tram and train. (PAUSE) |

ABC Radio Australia


© RadioAustralia/AMES 2008

**L1 Male:**

*មេរៀនទី១២ ឥឡូវនេះ ឈានចូលដល់ទីបញ្ចប់ហើយបាទ។ សូមលោកអ្នករង់ចាំស្ដាប់កម្មវិធីភាសាអង់គ្លេស សម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី មេរៀនទី១៣ស្ដីអំពី **"ការធ្វើកិច្ចការសាលាក្រុមគ្នា"** នៅក្នុងកម្មវិធីក្រោយទៀតបាទ។ ចំពោះមិត្តអ្នកស្ដាប់ដែលចង់បានមេរៀនថ្ងៃនេះ ព្រមទាំងឯកសារជំនួយមេរៀន ក៏ដូចជាលំហាត់សម្រាប់មេរៀននេះ លោកអ្នកអាចចូលទៅ វ៉ិបសាយថ៍របស់វិទ្យុអូស្ត្រាលី ដែលមានអាសយដ្ឋានដូចតទៅនេះ*

*radioaustralia.net.au/khmer*

***លោកអ្នកនាងកញ្ញា!*** *កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅអូស្ត្រាលីនេះ ចងក្រងឡើងដោយសេវាអប់រំពហុវប្បធម៌សម្រាប់មនុស្សពេញវ័យ នៅទីក្រុងមែលប៊ិន ប្រទេសអូស្ត្រាលី។ ចំពោះឯកសារ និងព័ត៌មានទាក់ទងនឹងការសិក្សាភាសាអង់គ្លេសផ្សេងៗទៀត របស់សេវាអប់រំពហុវប្បធម៌សម្រាប់មនុស្សពេញវ័យ លោកអ្នក អាចបើកមើលវ៉ិបសាយថ៍ ames.net.au។*

***សូមអរគុណ និងសូមគោរពលាមួយរយៈសិនបាទ!***

END OF LESSON 12

**ចប់មេរៀនទី១២**


© RadioAustralia/AMES 2008